ធនាគារជាតិ នៃ កម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ   សាសនា   ព្រះមហាក្សត្រ

លេខ..................................................

# សុន្ទរកថាស្វាគមន៍
# ឯកឧត្តម ជាចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសប្រារព្ធពិធីបើកសន្និសីទជាតិស្តីពី
# ការអភិវឌ្ឍនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

*វិមានសន្តិភាព ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦*

**សូមគោរព ៖**

- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សម្តេច ឯកឧត្តម លោកជំទាវ ជាគណៈអធិបតី ជាទីគោរព!
- អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ ជាទីស្នេហា!

ថ្ងៃនេះជាទិវាមួយដ៏មហោឡារិកដែលរាជរដ្ឋាភិបាល បានអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជា រៀបចំសន្និសីទជាតិស្តីពីការអភិវឌ្ឍនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ។ ជាមួយគ្នានេះ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់កិត្តិយសអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកសន្និសីទជាតិនាថ្ងៃនេះ ។ ខ្ញុំក៏សូមសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានគណៈអធិបតី សម្តេច ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងសន្និសីទជាតិនាពេលនេះ ។ វត្តមានដ៏វិសេសវិសាលរបស់ សម្តេច ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា ញុំាងឱ្យពិធីនេះដំណើរការកាន់តែមានភាពអធិកអធម មានអត្ថន័យយ៉ាងជ្រាលជ្រៅ និងបានបង្ហាញពីកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធថែមទៀត ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**សម្តេច ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់!**

សន្និសីទជាតិស្តីពីការអភិវឌ្ឍនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយពីសារៈសំខាន់អត្ថប្រយោជន៍និងតួនាទីរបស់វិស័យមីក្រូហិរញ្ញវត្ថុក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងកាត់បន្ថយភាពក្រីក្រ ដែលជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលរាយការណ៍ពីសមិទ្ធផលសម្រេចបានក្នុងរយៈពេល ១០ឆ្នាំ បន្ទាប់ពី សម្តេចតេជោនាយករដ្ឋមន្ត្រី បានប្រកាសយកឆ្នាំ២០០៦ជាឆ្នាំមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ក្នុងឱកាសនៃសន្និសីទជាតិស្តីពីមីក្រូហិរញ្ញវត្ថុកម្ពុជា ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១១-១៣ ខែមករា ឆ្នាំ២០០៦ ស្វែងយល់អំពីបញ្ហាប្រឈម និងកំណត់ទិសដៅសម្រាប់ការអភិវឌ្ឍនាពេលអនាគត ។

ខ្ញុំបាទសូមជម្រាបជូនថា បន្ទាប់ពីទទួលអនុសាសន៍ដ៏ថ្លៃថ្លារបស់ សម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា ក្រសួងពាក់ព័ន្ធ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានសហការយ៉ាងជិតស្និទ្ធដើម្បីអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុប្រកបដោយចីរភាព រួមចំណែកជំរុញបរិយាប័ន្នហិរញ្ញវត្ថុ លើកកម្ពស់ជីវភាពប្រជាជនតាមជនបទ និងជំរុញកំណើនសេដ្ឋកិច្ចពេញមួយទសវត្សរ៍កន្លងមក ។ ការរីកចម្រើននៃវិស័យនេះ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈកំណើននៃអត្រាបរិយាប័ន្នហិរញ្ញវត្ថុ ដែលត្រូវបានទទួលស្គាល់ថា ជាកម្លាំងចលកររួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ ជាក់ស្តែង ប្រជាជនពេញវ័យដែលកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុក្នុងប្រព័ន្ធ កើនពីប្រមាណ ៨,៧% នៅឆ្នាំ២០០៦ ដល់ប្រមាណ ៥១% ក្នុងឆ្នាំ២០១៥ ។ ឥណទានក្នុងវិស័យមីក្រូហិរញ្ញវត្ថុមានចំនួនប្រមាណ ១២ទ្រីលានរៀល (សមមូលនឹង ៣ ប៊ីលានដុល្លារអាមេរិក) កើនឡើងលើសពី៣០ដងធៀបនឹងឆ្នាំ២០០៦ និងប្រាក់បញ្ញើសរុបមានចំនួនប្រមាណ ៥ ទ្រីលានរៀល (សមមូលនឹង ១,៣ ប៊ីលានដុល្លារអាមេរិក) ។ គួរកត់សម្គាល់ដែរថា នៅឆ្នាំ២០០៩ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ឱ្យទទួលប្រាក់បញ្ញើពីសាធារណជន ក្នុងគោលបំណងជំរុញពិពិធកម្មសេវាហិរញ្ញវត្ថុ និងអន្តរការិយកម្មហិរញ្ញវត្ថុនៅតាមទីជនបទ ។ ជាមួយនឹងដែនសេវាទូទាំងប្រទេស វិស័យមីក្រូហិរញ្ញវត្ថុបាននិងកំពុងបង្កើនការផ្តល់សេវាហិរញ្ញវត្ថុជូនប្រជាពលរដ្ឋនៅទីជនបទដែលទទួលបានការអប់រំតិច ឱ្យទទួលបានលទ្ធភាពប្រើប្រាស់សេវាកម្មមានលក្ខណៈស្របច្បាប់ ការគាំពារកាន់តែប្រសើរ ការកាត់បន្ថយហានិភ័យ និងសមធម៌ក្នុងសង្គម ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរបញ្ញត្តិកម្មនិងត្រួតពិនិត្យប្រព័ន្ធធនាគារ បានដាក់ចេញបទប្បញ្ញត្តិមួយចំនួនដើម្បីធានាថាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តល់ហិរញ្ញប្បទានជូនអតិថិជន ប្រកបដោយការទទួលខុសត្រូវ

រួមមាន ការផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយទាក់ទិននឹងការប្រាក់ កម្រៃនានា មានលក្ខណៈស្តង់ដារ និងប្រកបដោយតម្លាភាពជាដើម ។ ទន្ទឹមនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនបាននិងកំពុងចូលរួមយ៉ាងសកម្ម ដោយបញ្ជ្រាបនូវគោលការណ៍ការពារអតិថិជនសំខាន់ៗ ជំរុញកម្មវិធីអប់រំផ្នែកហិរញ្ញវត្ថុ ជំនាញផ្សេងៗ និងការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពជូនដល់អតិថិជនរបស់ខ្លួន ។

កន្លងមក ទន្ទឹមនឹងការអភិវឌ្ឍរីកចម្រើនវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា មានអង្គការ សមាគម និងអ្នកឱ្យខ្ចីចងការក្រៅផ្លូវការមួយចំនួន បានឆ្លៀតឱកាសបង្កបញ្ហាដល់សង្គម ដូចជា ការផ្តល់កម្ចីដោយយកការប្រាក់ខ្ពស់ ធ្វើឱ្យកូនបំណុលរបស់ខ្លួនធ្លាក់ក្នុងគ្រោះអាសន្ន រើពីបំណុលមិនរួច ហិនហោចទ្រព្យសម្បត្តិ និងធ្លាក់ក្នុងភាពក្រីក្រ ។ ក្រៅពីនេះ ក៏មានអង្គការនិងសមាគមមួយចំនួនទៀត ប្រើប្រាស់ឈ្មោះនាមករណ៍ដូចជា **"ទីភ្នាក់ងារ"** ឬ **"អង្គការមនុស្សធម៌នានា"** ដែលអាចធ្វើឱ្យប្រជាពលរដ្ឋយល់ច្រឡំថាជារបស់រដ្ឋ ជាគ្រឹះស្ថានផ្តល់អំណោយមនុស្សធម៌ ឬមិនស្វែងរកប្រាក់ចំណេញ ។

ដូចនេះ ក្រោមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ បានសហការខ្ពស់រកដំណោះស្រាយចំពោះអង្គការ សមាគម និងអ្នកឱ្យខ្ចីចងការទាំងនោះ ។ ជាក់ស្តែងកាលពីដើមឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជានិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីថ្លែងការណ៍រួមមួយ ឱ្យផ្អាកសកម្មភាពអកុសលនេះភ្លាម ដើម្បីឆ្លើយតបទៅនឹងភាពមិនប្រក្រតីមួយចំនួនទាក់ទងនឹងប្រតិបត្តិករឥណទានក្រៅប្រព័ន្ធខ្លះ ដែលឆ្លៀតឱកាសប្រើឈ្មោះវិស័យមីក្រូហិរញ្ញវត្ថុធ្វើប្រតិបត្តិការកេងប្រវ័ញ្ច និងបង្កបញ្ហាដល់សង្គម ដោយជំរុញអង្គការនិងសមាគមឱ្យធ្វើសកម្មភាពក្នុងក្របខ័ណ្ឌច្បាប់ ។ ធនាគារជាតិនៃកម្ពុជាក៏បានសហការផងដែរជាមួយអាជ្ញាធរមូលដ្ឋាននានាតាមបណ្តាខេត្ត-រាជធានី ចំនួន ១៤ ដើម្បីចុះផ្សព្វផ្សាយដល់អាជ្ញាធរមានសមត្ថកិច្ចនិងប្រជាពលរដ្ឋ ឱ្យមានការយល់ដឹងកាន់តែច្បាស់លាស់ថែមទៀត ពីប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ដែលមានអ្នកចូលរួមសរុបចំនួន ៥.៧៦០ នាក់ ។ ជាមួយគ្នានេះ ចំពោះយុទ្ធនាការលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក៏កំពុងរៀបចំជាបន្តបន្ទាប់ សម្រាប់ផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធដូចជា សិស្ស និស្សិត ប្រជាជនតាមជនបទ និងអាជីវករនានាផងដែរ ។

សរុបមក ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ ជាមួយនឹងការអនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោនាយករដ្ឋមន្ត្រី វិស័យហិរញ្ញវត្ថុនៅកម្ពុជាមានការអភិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ជាខ្លាំង ទាំងផ្នែកវិសាលភាព ទំហំប្រតិបត្តិការ ផលិតផល និងបណ្តាញសេវាប្រជាជនយល់ដឹងពីសារៈសំខាន់នៃវប្បធម៌ឥណទាន និងបានលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ហើយវិស័យនេះក៏ត្រូវបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ។

មិនតែប៉ុណ្ណោះ វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាក៏ត្រូវបានទទួលស្គាល់ថា ជាវិស័យមីក្រូហិរញ្ញវត្ថុមួយដ៏រីកចម្រើនក្នុងពិភពលោក និងជាគំរូដ៏ល្អសម្រាប់បណ្តាប្រទេសដទៃទៀត ។ សមិទ្ធផលទាំងនេះ កើតឡើងដោយការខិតខំប្រឹងប្រែងរួមគ្នា និងកិច្ចសហការរវាងធនាគារជាតិនៃកម្ពុជាជាមួយអាជ្ញាធរពាក់ព័ន្ធ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ ជាពិសេសរាជរដ្ឋាភិបាល ដែលតែងតែបន្តគាំទ្រដល់ការអភិវឌ្ឍវិស័យទាំងមូល ។

**សម្តេច ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់!**

ជាកិច្ចបន្ត ខ្ញុំបាទសូមអនុញ្ញាតគោរពអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មានប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ ដើម្បីឱ្យយើងខ្ញុំនិងភាគីពាក់ព័ន្ធទាំងអស់ សហការអនុវត្តជាបន្តទៅទៀតប្រកបដោយជោគជ័យ ។

**សូមអរគុណ!**